**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ**: ៥៤០ ក.ប/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មដំឡូងមី

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ៨៧ ៩៨ ១០០ ១០៥ ១១១ និង១៣៨ នៃអង្គការអន្តរជាតិខាងការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅជានា ដកហូត ការពារ និងទប់ស្កាត់ កុមារពីការងារប្រកបដោយគ្រោះថ្នាក់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំនៅក្នុងមុខរបរផលិតកម្មដំឡូងមី ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៣៨, លេខ១៨២ និងច្បាប់ស្តីពីការងារ។

**ប្រការ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចតទៅ៖

- កុមារៈ សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ
- និយោជកៈ សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួលកុមារឲ្យធ្វើការ
- ការងារកុមារក្នុងផលិតកម្មដំឡូងមីៈ សំដៅលើការចូលរួមរបស់កុមារក្នុងដំណាក់កាលរៀបចំដី ដំណាក់កាលនៃ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ការដាំដុះការលូតលាស់របស់ដំឡូងមី ដំណាក់កាលប្រមូលផល និងបន្ទាប់ពីការប្រមូលផល

- **ការងារប្រកបដោយគ្រោះថ្នាក់:** សំដៅលើការងារទាំងឡាយណា ដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់កុមារ ដែលកើតឡើងក្នុងមុខរបរផលិតកម្មដំឡូងមី ព្រមទាំងបណ្តាលឲ្យប៉ះពាល់ដល់ រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំដូចមានជាអាទិ៍: ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី ការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ ការភ្ជួររាស់ និងការដកមើមដំឡូងចេញពីក្នុងដី។

**ប្រការ៣.-**

លក្ខខណ្ឌការងារកុមារក្នុងផលិតកម្មដំឡូងមីមានដូចតទៅ ៖

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំអាចអនុញ្ញាតឲ្យធ្វើការងារស្រាលបានក្នុងមុខរបរផលិតកម្មដំឡូងមី ប៉ុន្តែមិនឲ្យលើសពី ៤ម៉ោងក្នុងមួយថ្ងៃ ឬ១២ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃសិក្សា និងមិនឲ្យលើសពី ៧ម៉ោងក្នុងមួយថ្ងៃ ឬ៣៥ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃឈប់សម្រាក
- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំមិនអនុញ្ញាតឲ្យធ្វើការងារក្នុងមុខរបរផលិតកម្មដំឡូងមីជាប់គ្នារហូតលើសពី ៤ម៉ោង និង៣០នាទីដោយមិនមានការឈប់សម្រាក។ ការឈប់សម្រាកយ៉ាងហោចឲ្យបាន ៣០នាទីក្នុងមួយលើកៗ
- និយោជកត្រូវផ្តល់សម្ភារៈដល់កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម១៥ឆ្នាំ និងត្រូវមានវិធានការការពារក្នុងពេលធ្វើការងារក្នុងមុខរបរផលិតកម្មដំឡូងមី ដូចជា ម៉ាស់ និងស្រោមដៃ អាវភ្លៀង មួកពាក់ការពារកំដៅថ្ងៃ ជាក់ស្រោម ឬកាំបិតឲ្យជិតនៅពេលដាក់តាមខ្លួន ព្រមទាំងសម្ភារៈ និងប្រអប់សង្គ្រោះ
- ហាមកុមារដែលមានអាយុក្រោម ១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរផលិតកម្មដំឡូងមី ដូចមានជាអាទិ៍: ការប្រើប្រាស់សារធាតុពុលដែលមានជាតិគីមី និងការបាញ់ថ្នាំសម្លាប់សត្វល្អិតគ្រប់ប្រភេទ
- ហាមកុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំធ្វើការងារធ្ងន់ៗក្នុងមុខរបរផលិតកម្មដំឡូងមីដូចមានជាអាទិ៍: ការភ្ជួររាស់ និងការដកមើមដំឡូងចេញពីក្នុងដី
- ហាមកុមារដែលមានអាយុចន្លោះពី ១៥ឆ្នាំដល់ក្រោម១៨ឆ្នាំលើកដាក់ទម្ងន់លើសពី ៦គីឡូក្រាមសម្រាប់កុមារី និងលើសពី ១២គីឡូក្រាមសម្រាប់កុមារា ក្នុងមុខរបរផលិតកម្មដំឡូងមី
- ហាមឃាត់ដាច់ខាតការប្រើកុមារធ្វើការងារស្រាលៗ ចន្លោះពីម៉ោង ៨យប់ រហូតដល់ម៉ោង ៦ព្រឹក។

**ប្រការ៤.-**

កិច្ចអន្តរាគមន៍ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អធិការការងារ និងភាគីពាក់ព័ន្ធទាំងអស់ដែលត្រូវរួមគ្នាអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព និងមានចរិកលក្ខណៈជាពហុវិស័យ។

ក្នុងករណីប្រទះឃើញកុមារធ្វើការងារធ្ងន់ធ្ងរ និងប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរផលិតកម្មដំឡូងមី ភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវរាយការណ៍ជូនអធិការការងារ ដើម្បីចាត់វិធានការធ្វើការដកហូតកុមារតាមយន្តការនៃការបញ្ជូនទៅសាលារៀន បញ្ជូនទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាកម្មផ្សេងៗទៀត។

**ប្រការ៥.-**

ការអនុវត្តតួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងប្រកាសនេះ នាយកដ្ឋានការងារកុមារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវប្រើប្រាស់ថវិកាជាតិ និងធនធានផ្សេងៗទៀត ដែលទទួលបានពីសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារ។

អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៦.-**

និយោជកដែលមិនអនុវត្តតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**វង សុត**

**__ចម្លងជូន :__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- គ្រប់ក្រសួងពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

  "ដើម្បីអនុវត្ត"
- សមាគមនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព

  "ដើម្បីជូនជ្រាប"
- គ្រប់បណ្តាញសារព័ត៌មាន វិទ្យុនិងទូរទស្សន៍ និងភាគីពាក់ព័ន្ធទាំងអស់" ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ